គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខៈ ៣០៧ គ.ជ.ប. ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលបទបញ្ជា និងនីតិវិធី
## សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣
## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៩៩១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីការតែងតាំងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០៩៩ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្ដីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

- បានឃើញសេចក្តីសម្រេចលេខ ៤៣៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣
- យោងការអនុម័តរបស់ គ.ជ.ប នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣

## សម្រេច

**ប្រការមួយ.-**

សេចក្តីសម្រេចនេះ មានគោលបំណងកែសម្រួលបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ (ប.ន.ត.រ) ស្របតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត។

**ប្រការពីរ.-**

ត្រូវបានកែសម្រួលប្រការ៤.១ និងបន្ថែមប្រការ៤.១ថ្មី (ស្ទួន) ក្នុង ប.ន.ត.រ ដូចតទៅ៖

**ប្រការ៤.១.- ថ្មី**

អនុលោមតាមមាត្រា២៣ថ្មី ក្នុងមាត្រាពីរនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រជាពលរដ្ឋម្នាក់ៗត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

៤.១.១ មានសញ្ជាតិខ្មែរពីកំណើត។

៤.១.២ មានអាយុ ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត។

៤.១.៣ មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។

៤.១.៤ បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលចំនួន២ (ពីរ) លើកចុងក្រោយជាប់គ្នា ដែលរៀបចំឡើងដោយ គ.ជ.ប លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប។

៤.១.៥ មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

៤.១.៦ មានការតែងតាំងពីគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

បញ្ញត្តិដូចមានចែងក្នុងចំណុច៤.១.៤ ខាងលើនេះ ពុំមានអានុភាពដល់បញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ឡើយ។

**ប្រការ៤.១._ ថ្មី(ស្ទួន)**

មូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតពាក់ព័ន្ធនឹងលក្ខខណ្ឌដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដូចមានចែងក្នុងចំណុច៤.១.៤ នៃប្រការ៤.១ថ្មី ខាងលើនេះ ត្រូវបានកំណត់ដូចខាងក្រោមៈ

- ស្ថិតនៅក្រៅប្រទេស នៅថ្ងៃបោះឆ្នោត ដោយសារជាប់បំពេញបេសកកម្មផ្លូវការ ឬបំពេញការសិក្សា ឬបំពេញការងារដែលមានកិច្ចសន្យាការងារស្របច្បាប់
- មានជំងឺដែលមិនអាចទៅបោះឆ្នោតបាន នៅថ្ងៃបោះឆ្នោត
- ស្ត្រីសម្រាលកូន នៅថ្ងៃបោះឆ្នោត
- ត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្នស្របតាមច្បាប់ជាធរមាន
- ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបានស្របតាមបទប្បញ្ញត្តិនៃ ប.ន.ត.រ។

អ្នកបោះឆ្នោតដែលមិនបានអនុវត្តសិទ្ធិបោះឆ្នោត ដោយមូលហេតុសមស្របដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ហើយមានបំណងឈរឈ្មោះបោះឆ្នោត ត្រូវបញ្ជាក់ពីមូលហេតុ និងត្រូវមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ដល់ គ.ជ.ប។

**ប្រការបី._**

បទប្បញ្ញត្តិនៃជំពូកទី៨នៃ ប.ន.ត.រ ពាក់ព័ន្ធនឹងបែបបទ និងនីតិវិធីនៃការវេចខ្ចប់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការិយាល័យបោះឆ្នោត ព្រមទាំងការបញ្ជូន ការត្រួតពិនិត្យ និងការរៀបចំទិន្នន័យអ្នកដែលបានមកបោះឆ្នោត ត្រូវបានកែសម្រួល និងកំណត់ជាថ្មី ដោយសេចក្តីណែនាំរបស់ គ.ជ.ប។

**ប្រការបួន._**

សម្រង់មាត្រា១៤២ និងមាត្រា១៤៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា១៧១ និងមាត្រា១៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចែងក្នុងឧបសម្ព័ន្ធនៃ ប.ន.ត.រ ត្រូវបានកែសម្រួលទៅជា “មាត្រា១៤២ថ្មី” “មាត្រា១៤៣ថ្មី” “មាត្រា១៧១ថ្មី” និង “មាត្រា១៧២ថ្មី” ដែលមានខ្លឹមសារដូចមានចែងក្នុងមាត្រាពីរ និងមាត្រាបីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត។

ប្រការ ចំណុច និងឧបសម្ព័ន្ធនៃ ប.ន.តរ ដែលមានចែងយោងមាត្រា២៣ មាត្រា២៦ មាត្រា៣១ មាត្រា៣២ មាត្រា១៣៥ មាត្រា១៣៨ និងមាត្រា១៣៨ស្ទួន ត្រូវបានកែសម្រួលទៅជា “មាត្រា២៣ថ្មី” “មាត្រា២៦ថ្មី” “មាត្រា៣១ថ្មី” “មាត្រា៣២ថ្មី” “មាត្រា១៣៥ថ្មី” “មាត្រា១៣៨ថ្មី” និង “មាត្រា១៣៨ស្ទួនថ្មី” ស្របតាមមាត្រាប្រាំមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

អគ្គលេខាធិការ គ.ជ.ប និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ

**កន្លែងទទួល :**

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ក្រសួងមហាផ្ទៃ
- គណបក្សនយោបាយ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ